

# កម្មវិធីអាហារូបករណ៍
# អភិវឌ្ឍវិញ្ញត្តិវប្បធម៌

## សេចក្ដីប្រកាសទទួលពាក្យ

ផុតកំណត់ទទួលពាក្យថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២២

រៀបចំដោយ៖

CAMBODIAN LIVING ARTS

សមាគមស៊ីភាដា

គាំទ្រដោយ៖

ស៊ុយអែត Sverige

unesco Diversity of Cultural Expressions

# ទិដ្ឋភាពទូទៅ

សមាគមដើម្បីការអភិវឌ្ឍន៍ និងការគាំទ្រឧស្សាហកម្មកែច្នៃនៃកម្ពុជា (សមាគមស៊ីកាដា) និងអង្គការសិល្បៈខ្មែរអមតៈរីករាយនឹងប្រកាសកម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ ដែលជាកម្មវិធីថ្មីបង្កើតឡើងជាពិសេសសម្រាប់អ្នកកំពុងធ្វើការក្នុង និងក្រៅវិស័យសិល្បៈវប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋនៅប្រទេសកម្ពុជា។

សិល្បៈខ្មែរអមតៈ និងស្ថាប័នសិល្បៈ/វប្បធម៌ចំនួន ៥ ផ្សេងទៀត បានរួមគ្នាបង្កើតសមាគមស៊ីកាដា ដែលបានចុះឈ្មោះជាផ្លូវការនៅឆ្នាំ២០២២ បន្ទាប់ពីសហគមន៍សិល្បៈបានចូលរួមក្នុងជំនួបប្រជុំពិគ្រោះយោបល់ជាច្រើនដង ដើម្បីស្វែងរកការគាំទ្រដល់វិស័យសិល្បៈក្នុងឆ្នាំ២០២០ និង ២០២១។ ទស្សនវិស័យរបស់សមាគមដើម្បីការអភិវឌ្ឍ និងការគាំទ្រឧស្សាហកម្មកែច្នៃនៃកម្ពុជា គឺចង់មើលឃើញសង្គមកម្ពុជារីកចម្រើនប្រកបដោយភាពចម្រុះនៅពេលដែលឧស្សាហកម្មច្នៃប្រតិដ្ឋ និងវប្បធម៌ត្រូវបានផ្តល់តម្លៃ និងទទួលបាននូវភាពរីកចម្រើនឈានទៅរកសក្តានុពលខ្ពស់បំផុត។ ដូចនេះ ដើម្បីបន្តគាំទ្រដល់វិស័យសិល្បៈ វប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋ អាហារូបករណ៍នេះបង្កើតឡើង ដើម្បីធនធានមនុស្សនៅក្នុងវិស័យនេះមានលទ្ធភាពកាន់តែប្រសើរឡើងក្នុងការអភិវឌ្ឍ និងគាំទ្រវិស័យនេះ។

តាមរយៈការសិក្សាមួយស្តីពីការស្ទង់មតិអំពីតម្រូវការជំនាញក្នុងចំណោមអតីតអ្នកទទួលអាហារូបករណ៍ទស្សនវប្បធម៌ និងសិល្បករមួយចំនួន ពួកគេត្រូវការជំនាញចាំបាច់ដូចជា ជំនាញប្រមូល ចងក្រង និងវិភាគទិន្នន័យ ការចងបណ្តាញដៃគូ និងជំនាញគៀងគរការគាំទ្រជាដើម។ ជំនាញទាំងនេះសុទ្ធសឹងតែជាជំនាញ ដែលឆ្លើយតបនឹងជំនាញសំខាន់ៗ ស្របនឹងកម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌នេះ។

ដូចនេះ កម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌បើកប្រកាសជ្រើសរើសសិល្បករ អ្នកនិពន្ធ ប្រតិបត្តិករវប្បធម៌ (អ្នកដំឡើងពិព័រណ៍ អ្នករៀបចំមហោស្រព អ្នកគ្រប់គ្រងសិល្បៈសហគមន៍ អ្នកស្រាវជ្រាវវប្បធម៌ អ្នកបោះពុម្ព...) និងអ្នកធ្វើការក្រៅរង្វង់សិល្បៈ តែប្រើប្រាស់សិល្បៈជាមធ្យោបាយ ដើម្បីដាក់ពាក្យចូលរួមក្នុងកម្មវិធីអាហារូបករណ៍នេះ។

# គោលដៅនៃកម្មវិធី

កម្មវិធីអាហារូបករណ៍ថ្មីនេះផ្តោតលើគោលនយោបាយវប្បធម៌ និងការតស៊ូមតិគាំទ្រ និងមានគោលបំណងពង្រឹងចំណេះដឹងចាំបាច់នានា ដើម្បីបង្កើនធនធានមនុស្សក្នុងវិស័យសិល្បៈវប្បធម៌ ដែលមានចំណាប់អារម្មណ៍ជាអ្នកគាំទ្រសិល្បៈ និងតស៊ូមតិគាំទ្រដល់វិស័យសិល្បៈ។

ជំនាញទាំងនេះនឹងរៀបចំផ្តល់ជូនតាមរយៈសិក្ខាសាលាអន្តរសកម្មភាព បទបង្ហាញរបស់អ្នកជំនាញ បង្វឹកហាត់ជាមួយគ្រូបង្វឹក ពិភាក្សាជាក្រុម ការធ្វើការងារលើគម្រោងរួម បទបង្ហាញពីអ្នកជំនាញខាងគោលនយោបាយវប្បធម៌ថ្នាក់តំបន់ និងឱកាសក្នុងការអនុវត្តនូវជំនាញទាំងនេះតាមរយៈបទបង្ហាញនាចុងបញ្ចប់វគ្គផងដែរ។

អ្នកទទួលអាហារូបករណ៍មិនចាំបាច់មានបទពិសោធន៍នឹងការងារតស៊ូមតិគាំទ្រ ឬគោលនយោបាយវប្បធម៌ទេ តែពួកយើងត្រូវការចំណាប់អារម្មណ៍ និងការចង់ចេះចង់ដឹង និងក្តីស្រឡាញ់ក្នុងការគាំទ្រវិស័យសិល្បៈវប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋ។

**គោលបំណងរបស់កម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌មានដូចតទៅ៖**

- អ្នកទទួលអាហារូបករណ៍ទទួលបាននូវចំណេះដឹងអំពីប្រព័ន្ធអេកូនៃគោលនយោបាយវប្បធម៌ និងបទពិសោធន៍អំពីការតស៊ូមតិគាំទ្រ
- អ្នកទទួលអាហារូបករណ៍ទទួលបានបទពិសោធន៍ និងជំនាញងាយស្រួលអនុវត្ត ក្នុងការប្រមូលស្វែងរកទិន្នន័យ ការវិភាគ និងប្រើប្រាស់ទិន្នន័យ
- ផ្តល់ជូនអ្នកទទួលអាហារូបករណ៍នូវជំនាញសំខាន់ៗសម្រាប់ការងារទាក់ទងនឹងទិន្នន័យ និងការស្រាវជ្រាវ
- កសាងបណ្តាញដៃគូក្នុងសហគមន៍សិល្បៈ ដៃគូមកពីវិស័យអភិវឌ្ឍផ្សេងៗ ដើម្បីអាចធ្វើការជាមួយគ្នា និងគាំទ្រគ្នាទៅវិញទៅមក

# លក្ខខណ្ឌនៃការជ្រើសរើស

ពួកយើងស្វែងរកបេក្ខជនជាពលរដ្ឋកម្ពុជា (ឬកាន់ទិដ្ឋការ K-Visa) កំពុងស្នាក់នៅប្រទេសកម្ពុជា និងមានបទពិសោធន៍ការងារយ៉ាងតិច ពីរ ទៅ បីឆ្នាំ ចំនួន ៨ នាក់ និងមានលក្ខណៈសម្បត្តិដូចតទៅ៖

- ជាអ្នកធ្វើការក្នុងវិស័យសិល្បៈ វប្បធម៌ (សិល្បករ អ្នកគ្រប់គ្រងកម្មវិធី អ្នកដំឡើងពិព័រណ៍ អ្នករៀបចំមហោស្រព អ្នកនិពន្ធ...) ដែលមានតួនាទី និងបទពិសោធន៍ដឹកនាំសកម្មភាពសិល្បៈ/វប្បធម៌ និងវិស័យអភិវឌ្ឍសង្គម
- ជាអ្នកដែលបានចូលរួមចំណែក និងអាចបង្ហាញអំពីចំណាប់អារម្មណ៍ខ្ពស់ទៅលើការងារតស៊ូមតិ
- អ្នកដែលមានជំនឿថា សិល្បៈគឺជាវិស័យដ៏សំខាន់មួយសម្រាប់ការអភិវឌ្ឍប្រទេសកម្ពុជា

ភាសាខ្មែរនឹងត្រូវប្រើប្រាស់ជាចម្បងសម្រាប់កម្មវិធីនេះ។ ចំណេះដឹងភាសាអង់គ្លេសមិនជាចាំបាច់ទេ។ យើងនឹងមានអ្នកសម្របសម្រួលភាសា សម្រាប់បទបង្ហាញអំពីគោលនយោបាយវប្បធម៌ថ្នាក់តំបន់។

# អត្ថប្រយោជន៍ដែលសិក្ខាកាមនឹងទទួលបាន

**អត្ថប្រយោជន៍ដែលអ្នកទទួលអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ មានដូចជា៖**

- ឱកាសចងដៃគូជាមួយប្រតិបត្តិករវប្បធម៌ ដែលមានគំនិត និងចំណាប់អារម្មណ៍អំពីវប្បធម៌ គោលនយោបាយវប្បធម៌ តួនាទី និងគុណតម្លៃសិល្បៈ និងវប្បធម៌មកលើសង្គម
- ឈ្វេងយល់ និងហ្វឹកហាត់អនុវត្តជំនាញតស៊ូមតិ ការប្រមូល និងវិភាគទិន្នន័យ ជំនាញទំនាក់ទំនង និងគោលនយោបាយវប្បធម៌នៅកម្ពុជា និងបណ្ដាប្រទេសថ្នាក់តំបន់
- ឱកាសទទួលបានការប្រឹក្សាពីអ្នកជំនាញ ដែលអញ្ជើញមកជាវាគ្មិន ធ្វើបទបង្ហាញអំពីបទពិសោធន៍ជាក់ស្តែងទាក់ទងនឹងការងារតស៊ូមតិ
- បានចូលរួមបទបង្ហាញចែករំលែកពីអ្នកជំនាញខាងគោលនយោបាយវប្បធម៌ថ្នាក់តំបន់
- ក្លាយជាសមាជិកសមាគមស៊ីកាដា និងជាអ្នកគាំទ្រ បណ្ដាញសហគមន៍ដៃគូក្នុងវិស័យសិល្បៈ វប្បធម៌ និងឧស្សាហកម្មច្នៃប្រតិដ្ឋ
- ទទួលបានប្រាក់លើកទឹកចិត្តចំនួន ៥០០ ដុល្លារក្នុងម្នាក់

# សេចក្តីបន្ថែមអំពីកម្មវិធី

កម្មវិធីនេះចែកចេញជា ៤ ផ្នែកសំខាន់ៗ ពោលគឺ៖ ១) ពិធីស្វាគមន៍ និងសិក្ខាសាលាណែនាំអំពីកម្មវិធី ២) សិក្ខាសាលាជំនាញចំនួន ៤, ៣) ការងារជាក្រុម និងបទបង្ហាញនៃការងារក្រុម, ៤) បទបង្ហាញអំពីគោលនយោបាយវប្បធម៌ថ្នាក់តំបន់ (អនឡាញ)។ នៅចុងបញ្ចប់នៃកម្មវិធី អ្នកទទួលអាហារូបករណ៍នឹងត្រូវប្រជុំ ដើម្បីឆ្លុះបញ្ចាំងពីកម្មវិធី។

## 1 ពិធីស្វាគមន៍ និងសិក្ខាសាលាណែនាំអំពីកម្មវិធី

- ពិធីស្វាគមន៍នឹងរៀបចំឡើងនៅល្ងាចថ្ងៃទី ២៨ តុលា ដើម្បីណែនាំអ្នកទទួលអាហារូបករណ៍ វាគ្មិន អ្នកសម្របសម្រួល និងដៃគូសហការនានាអំពីកម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌។
- នៅថ្ងៃទី ២៩ តុលា នឹងមានសិក្ខាសាលារយៈពេលមួយថ្ងៃ ដើម្បីណែនាំទូទៅអំពីកម្មវិធីលម្អិត និងពិភាក្សាទៅលើពាក្យគន្លឹះមួយចំនួន។

## 2 សិក្ខាសាលាជំនាញ

សិក្ខាសាលានីមួយៗមានរយៈពេលពីរថ្ងៃកន្លះនៅក្រុងភ្នំពេញ។ កាលបរិច្ឆេទសំខាន់ៗរួមមាន៖

- សិក្ខាសាលាទី ១ «វិធីសាស្ត្រប្រមូលទិន្នន័យ» ២៥- ២៧ វិច្ឆិកា ២០២២
- សិក្ខាសាលាទី ២ «ការវិភាគទិន្នន័យ និងការបង្កើតផែនការយុទ្ធសាស្ត្រ» ៦ - ៨ មករា ២០២៣
- សិក្ខាសាលាទី ៣ «ការកសាងបណ្តាញដៃគូ និងយុទ្ធសាស្ត្រនៃការកៀងគរការគាំទ្រ» ៣ - ៦ កុម្ភៈ ២០២៣
- សិក្ខាសាលាទី៤ «យុទ្ធសាស្ត្រនៃការផ្សព្វផ្សាយ និងទំនាក់ទំនង» ៣ - ៥ មីនា ២០២៣

## 3 ការងារក្រុម និងបទបង្ហាញនៃការងារក្រុម

- នៅក្នុងសិក្ខាសាលានីមួយៗ អ្នកទទួលអាហារូបករណ៍នឹងត្រូវផ្តល់ឱកាស (នៅថ្ងៃទីបីនៃថ្ងៃសិក្ខាសាលារយៈពេលកន្លះថ្ងៃ) ដើម្បីបានជជែកពិភាក្សា និងធ្វើការងារជាក្រុម។
- ដោយយល់ថាវិស័យសិល្បៈ និងវប្បធម៌ជាទុនយ៉ាងសំខាន់សម្រាប់វិស័យទេសចរណ៍ ដែលជាចំណែកដ៏សំខាន់នៃការអភិឌ្ឍសេដ្ឋកិច្ចជាតិ ដែលវិស័យទាំងពីរនេះរឹតតែមានសក្តានុពលប្រសើរឡើង ប្រសិនបើផែនការអភិវឌ្ឍយុទ្ធសាស្ត្រាប់បញ្ចូលវិស័យទាំងពីរនេះ។ ដូចនេះ កម្មវិធីអាហារូបករណ៍នេះនឹងជ្រើសរើសប្រធានបទ «ផែនការកៀងគរការគាំទ្រដើម្បីរាប់បញ្ចូលវិស័យសិល្បៈវប្បធម៌ក្នុងផែនការយុទ្ធសាស្ត្រនៃវិស័យទេសចរណ៍»។
- ក្នុងពេលការងារក្រុមនីមួយៗ អ្នកទទួលអាហារូបករណ៍នឹងចែកជាពីរក្រុម (មួយក្រុមមានបួននាក់) និងមួយក្រុមមានអ្នកជំនាញម្នាក់សម្រាប់ជួយប្រឹក្សាយោបល់។ ក្រុមនីមួយៗនឹងទទួលបានថវិការហូតដល់ ១០០០ ដុល្លារ ដើម្បីសម្រួលដល់ការរៀបចំការងារក្រុម។ក្រុមនីមួយៗនឹងត្រូវដាក់ស្នើថវិកាសម្រាប់ការងារក្រុមទៅតាមការចាំបាច់ និងប្រសិទ្ធភាពនៃការអនុវត្តការងារក្រុម។
- នៅចុងបញ្ចប់កម្មវិធី អ្នកទទួលអាហារូបករណ៍នឹងត្រូវធ្វើបទបង្ហាញជូនដៃគូអញ្ជើញមកពីស្ថាប័នរដ្ឋ ស្ថាប័នសិល្បៈ និងស្ថាប័នមួយចំនួនទៀត។

## 4 បទបង្ហាញអំពីគោលនយោបាយវប្បធម៌ថ្នាក់តំបន់

- អ្នកទទួលអាហារូបករណ៍នឹងត្រូវចូលរួមក្នុងបទបង្ហាញអំពីគោលនយោបាយវប្បធម៌ថ្នាក់តំបន់ ដែលនឹងរៀបចំឡើងមួយខែម្តង មានរយៈពេលពីរម៉ោងតាមប្រព័ន្ធហ្ស៊ូម។ វាគ្មិនដែលមានបទពិសោធន៍នឹងគោលនយោបាយវប្បធម៌ថ្នាក់តំបន់នឹងអញ្ជើញមកធ្វើបទបង្ហាញ ដើម្បីបង្កើនការយល់ដឹងអំពីរូបភាពទូទៅ ការអភិវឌ្ឍ និងករណីសិក្សានានា នៃគោលនយោបាយវប្បធម៌។ ក្រៅពីអ្នកទទួលអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ អតីតអ្នកទទួលអាហារូបករណ៍ទស្សនវប្បធម៌ក៏អាចចូលរួមក្នុងបទបង្ហាញនេះផងដែរ។ កម្មវិធីនេះនឹងមានការបកប្រែជូន។ ក្រុមការងារនឹងពិគ្រោះជាមួយអ្នកទទួលអាហារូបករណ៍អំពីកាលបរិច្ឆេទដែលសមស្របមួយសម្រាប់បទបង្ហាញនេះ។

ក្រៅពីកម្មវិធីបួនធំៗនេះ នៅចុងបញ្ចប់នៃកម្មវិធី អ្នកទទួលអាហារូបករណ៍នឹងត្រូវជួប និងប្រជុំឆ្លុះបញ្ចាំងពីកម្មវិធី។



# ការដាក់ពាក្យ

ដើម្បីដាក់ពាក្យចូលរួមក្នុងកម្មវិធីនេះ បេក្ខជនត្រូវផ្ញើពាក្យស្នើសុំ ដែលបានផ្តល់ជូនជាមួយសេចក្តីប្រកាសនេះ។ បេក្ខជនអាចទាញយកពាក្យស្នើសុំតាមគេហទំព័ររបស់សមាគមស៊ីកាដា ឬពីការិយាល័យសិល្បៈខ្មែរអមតៈរាល់ម៉ោងធ្វើការ។ ពាក្យស្នើសុំត្រូវមានចម្លើយគ្រប់សំណួរទាំងអស់ និងសូមផ្ញើទៅ cci@cambodianlivingarts.org។ ប្រសិនបើបេក្ខជនមានការពិបាកក្នុងការដាក់ពាក្យ បេក្ខជនអាចទូរស័ព្ទមកសាគុណ តាមរយៈលេខទូរស័ព្ទ 012 43 22 01។

កម្មវិធីនេះនឹងមានគណៈកម្មការជ្រើសរើស ដែលអញ្ជើញមកពីស្ថាប័នសិល្បៈ វប្បធម៌ និងមកពីសមាគមដើម្បីការអភិវឌ្ឍន៍ និងការគាំទ្រឧស្សាហកម្មកៃច្នៃនៃកម្ពុជា (CICADA)។ បេក្ខជននឹងទទួលបានលទ្ធផលនៅក្នុងអំឡុងសប្តាហ៍ទីមួយនៃខែតុលា។

លោកអ្នកអាចឈ្វេងយល់អំពីកម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌ តាមរយៈកម្មវិធីសំណួរចម្លើយដែលរៀបចំដោយអង្គការសិល្បៈខ្មែរអមតៈនៅថ្ងៃទី ០២ កញ្ញា ២០២២ ចាប់ពីម៉ោង ៥.៣០ ល្ងាច។ សូមចុះឈ្មោះតាមតំណភ្ជាប់៖ https://forms.gle/VT3ccMwZ8Nfbf66q9

កាលបរិច្ឆេទឈប់ទទួលពាក្យគឺថ្ងៃទី ៣០ ខែកញ្ញា ឆ្នាំ ២០២២។

សម្គាល់៖ កម្មវិធីអាហារូបករណ៍អភិវឌ្ឍវិញ្ញត្តិវប្បធម៌គាំទ្រផ្នែកហិរញ្ញវត្ថុដោយមូលនិធិអន្តរជាតិសម្រាប់ភាពផ្សេងៗគ្នានៃវប្បធម៌ និងភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអ៊ែត (ស៊ីដា)។